# រឿងភិក្ខុកូនសេដ្ឋី

(គូព្រេងធ្លាប់សាងជាមួយពីដើមមកមិនដែលព្រាត់)

កាល ពីព្រេងនាយ បុរាណបណ្ឌិតបានដំណាលថា មានភិក្ខុ ១ រូបជាកូនសេដ្ឋី មានទ្រព្យសម្បត្តិច្រើន ។ ថ្ងៃមួយសេដ្ឋីជាបិតា របស់ភិក្ខុមកធ្វើបុណ្យក្នុងវត្តនោះ មានខ្ញុំស្រីម្នាក់មានកូនតូច ទើបនឹងចេះដើរបន្តិចៗ ជាប់តាមមកបំរើសេដ្ឋីនោះ នាងខ្ញុំសេដ្ឋីនោះ ក៏ទៅចងអង្រឹងឲ្យកូនដេក ក្រោមកុដិភិក្ខុនោះ ។ ជួនជាពេល នោះ មានតាចាស់ម្នាក់ចេះទាយមើលគូព្រេង ក៏ឡើងមកលេងសប្បាយនឹងភិក្ខុ នោះ និយាយពីនេះពីនោះយូរបន្តិច ក៏ភិក្ខុនោះរកតានោះមើលគូព្រេងឲ្យ ។

តានោះក៏ពិនិត្យមើលតាមដំណើរក្បួនឃើញច្បាស់ ហើយក៏និយាយថា លោក ចៅកុំអន់ចិត្តនឹងតា ទើបតាហ៊ានទាយឲ្យបាន ។ លោកនោះថាកុំព្រួយ អាត្មាមិន អន់ចិត្តទេ អាណិតតែទាយឲ្យត្រឹមត្រូវចុះ ។ ទើបតានោះទាយថា លោកចៅទៅ វិញ មុខជានឹងបានប្រពន្ធកូនខ្ញុំគេជាប្រាកដ ។ លោកនោះឮហើយក៏ធ្លាក់ទឹកមុខ មិនសប្បាយចិត្តសោះ ទើបសួរដេញដោលទៅទៀតថា កូនហ្នឹងតើកើតហើយ ឬនៅ ? តានោះប្រាប់ថាកើតហើយ គេបានទាំងនាំយកមកក្នុងកំឡុងពេលបុណ្យ នេះទៀតផង ។ តាគ្រូទាយហើយក៏លាចុះទៅបាត់ ។

ក្រោយពីនោះមកភិក្ខុនោះថា មានកូនអ្នកណាជាកូនខ្ញុំស្រីម្នាក់ដែលតាមបំរើមា តា បិតា ហើយយកមកទាំងកូនស្រីតូចមកចងអង្រឹង ឲ្យដេកក្រោមកុដិរបស់ខ្លួន ក៏សន្និដ្ឋានថាច្បាស់ជាកូនស្រីហ្នឹងហើយដែលតាគ្រូទាយថា គូព្រេងរបស់អា ត្មាអញ លោកនេះក្តៅចិត្តខ្លាំងពេកទប់ចិត្តពុំបាន ក៏ស្ទុះទៅយកកាំបិតចុងស្រួច មក ហើយវែករនាបកុដិបោះកាំបិតឰយចុងសំយុងសំដៅទៅកូនក្នុងអង្រឹង នោះ ដើម្បីឲ្យមុតស្លាប់ ចុងកាំបិតនោះមិនបានត្រូវត្រង់កន្លែងដំណំឡើយ គ្រាន់តែត្រូវ ឆើយឆិតរលាត់ស្បែកពោះបន្តិចល្មមមានស្នាម កូននោះក៏ស្រែកយំផ្អើលអស់ មនុស្សដែលមកបុណ្យទាំងប៉ុន្មាន រួចហើយភិក្ខុនោះក៏គេចពីវត្តបាត់ទៅ ។

ឯម្តាយកាលបើឮមាត់កូនយំក៏ស្ទុះមកលើកូនបីត្រកងឡើង ឃើញឈាមក៏ អាណិតកូនយ៉ាងក្រៃលែង នាងនោះអន់ចិត្តពេក ក៏លាលោកសេដ្ឋីនោះ លែង បំរើ ហើយដើរទៅរកសុំបំរើត្រកូលអ្នកមានទ្រព្យសម្បត្តិ ដែលនៅស្រុកឆ្ងាយ

ផ្សេងទៀត ។ លុះយូរដល់ជិត ២០ ឆ្នាំ សេដ្ឋីជាមាតា បិតា របស់ភិក្ខុនោះក៏ស្លាប់បាត់បង់ទៅ ឯទ្រព្យសម្បត្តិទាំងប៉ុន្មាន ក៏វិនាសអន្តរាយអស់គ្មានសល់ ភិក្ខុនោះក៏សឹកទៅវិញ ធ្លាក់ខ្លួនជាអ្នកទីទ័លក្រលំបាក ដើរស៊ីឈ្នួលគេចិញ្ចឹមជីវិត ក៏បានទៅជួបនាងទាំងពីរអ្នក គឺម្ដាយនិងកូនដែលនៅបំរើគេនោះ ។ អ្នកបណ្ឌិតនោះក៏មិនស្គាល់សោះ លុះឃើញកាលណាក៏មានចិត្តប្រតិព័ទ្ធស្នេហាចង់បានជាភរិយា ឯត្រកូលទាំងពីរនាក់នឹងម្ដាយនាងនោះក៏ សុខចិត្តព្រម ទើបរៀបការផ្សំផ្គុំកូនស្រីនោះជាមួយនិងអ្នកបណ្ឌិត ឱ្យជាស្វាមីភរិយានឹងគ្នា ។

លុះដល់វេលារាត្រីនឹងចូលដេក ប្ដីនោះក្រឡេកឃើញស្នាមត្រង់ពោះប្រពន្ធហើយក៏សួរថា ចុះហេតុអ្វីបានជានាងមានស្លាកស្នាមយ៉ាងនេះ ប្រពន្ធក៏ប្រាប់ថា ម្ដាយគាត់បានប្រាប់ខ្ញុំថាកាលខ្ញុំនៅតូចទើបនឹងចេះដើរបន្តិចៗ គាត់នាំយកទៅឲ្យដេកក្រោមកុដិលោកសង្ឃ មានភិក្ខុមួយរូបនៅក្នុងកុដិនោះ ត្រូវឮគ្រូទាយថាលោកសឹកទៅនឹងបានការប្រពន្ធ ជាកូនខ្ញុំគេមិនខានក៏កើតទោមនស្សអន់ចិត្ត ទើបទាញកាំបិតចុងស្រួចបោះពួយទំលាក់ពីលើកុដិទៅលើខ្លួនខ្ញុំ ហើយក៏ត្រូវឆិតរលាត់ស្បែកពោះ ព្រោះហេតុនោះបានជាជាប់មានស្លាកស្នាមមកដល់សព្វថ្ងៃ ។ ប្ដីនោះឮហើយក៏ភ្ញាក់ខ្លួនព្រឺតគិតថា អាត្មាអញនឹងទេតើដែលកាលនៅបព្វជិតបានគិតប្រុងនឹងសម្លាប់នាងនេះមែន ឯអ្នកទាំងពីរនោះលុះរួមរស់នឹងគ្នាយូរទៅ ក៏បានឡើងជាអ្នកមានទ្រព្យសម្បត្តិច្រើន ។

សូមអស់លោកអ្នកអនុមោទនា!

(ចប់)